# សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពពិភពលោក

ភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

មានពាក្យចចាមអារាមមួយចំនួនបានផ្សព្វផ្សាយចេញជាសាធារណៈថា មានប្រជាជនកម្ពុជាជាច្រើនបានឆ្លងជំងឺផ្តាសាយថ្មីរាតត្បាតជាសកល A/H1N1 បន្ទាប់ពីពួកគេធ្វើដំណើរត្រលប់មកពីប្រទេសថៃ និងដែលមានស្លាប់ចំនួន ១ ទៅ ៦ នាក់ ។ ក្រសួងសុខាភិបាលសូមបំភ្លឺជូនដល់សាធារណជនថា ចាប់តាំងពីមានករណីទីមួយ ដែលបានរកឃើញនៅខែមិថុនា រហូតពេលនេះយើងមានចំនួនជំងឺផ្តាសាយ A/H1N1 សរុបទាំងអស់ ១៧ ករណី នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនោះចំនួន ១៦ករណីសុទ្ធតែបាន ធ្វើដំណើរមកពីប្រទេសក្រៅ ឬបានប៉ះពាល់ ជាមួយអ្នកធ្វើដំណើរដូចគ្នា ។ គ្រប់ករណីទាំងអស់ត្រូវបានដាក់ដោយឡែក ពីប្រជាជនដទៃ និងបានទទួលការព្យាបាល ពួកគេទាំងអស់នោះបានជាសះស្បើយហើយ ។ ក្រសួងសុខាភិបាលមានប្រព័ន្ធតាមដានជំងឺឆ្លង ជាស្រេចដើម្បីតាមដានរុករកករណីជំងឺផ្តាសាយ ។ ជាបន្ថែម រាល់អ្នកដំណើរដែលចូលមកពីប្រទេសក្រៅ ត្រូវបានស្នើសុំឱ្យបំពេញទំរង់ប្រកាសសុខភាព ឬ ពិនិត្យមើលសីតុណ្ហភាព ។

ក្រសួងសុខាភិបាល បានធ្វើការតាមដានយ៉ាងល្អិតល្អន់បំផុត អំពីស្ថានភាព និង មានប្រព័ន្ធទាក់ទងជាប្រចាំរវាងក្រសួងសុខាភិបាល និង មន្ទីរសុខាភិបាល គ្រប់ខេត្ត រាជធានី ដើម្បីតាមដានពីស្ថានភាពជំងឺនេះ។

**<u>ដំបូន្មានអប់រំសុខភាពសាធារណៈ:</u>**

ក្រសួងសុខាភិបាល និង អង្គការសុខភាពពិភពលោក សូមផ្តល់ដំបូន្មាន ដល់សាធារណជនថា ដើម្បីបង្ការចំលងជំងឺផ្តាសាយ ថ្មី A/H1N1 សូមអនុវត្តនូវអនាម័យជាមូលដ្ឋានគ្រប់ពេលវេលាទាំងអស់ដូចខាងក្រោមនេះ :

- ខ្ទប់មាត់ ច្រមុះ ដោយក្រដាស ឬ កន្សែង នៅពេលក្អក ឬ កណ្តាស
- លាងដៃជាមួយទឹក និង សាប៊ូ (ជាពិសេសបន្ទាប់ ពីក្អក កណ្តាស និង មុនបរិភោគ)
- កុំខាកស្តោះនៅទីសាធាណៈ

រោគសញ្ញាជំងឺផ្តាសាយថ្មី A/H1N1 រួមមាន គ្រុនក្តៅលើសពី ៣៨ អង្សារសេ និង ក្អក, ហៀរសំបោរ, ឈឺក, ដកដង្ហើមហត់ និង អស់កំលាំងល្ហិតល្ហៃ ។ ជនទាំងឡាយណាមានរោគសញ្ញាដូចខាងលើគួរស្នាក់នៅផ្ទះ, ចៀសវាងកន្លែងមានមនុស្ស កកកុញ ។ បច្ចុប្បន្ននេះ ពុំទាន់មានវ៉ាក់សាំង សំរាប់ចាក់បង្ការជំងឺផ្តាសាយថ្មី A/H1N1 នៅឡើយទេ ហើយករណីឈឺ ភាគច្រើនពុំចាំ បាច់ព្យាបាលដោយឱសថប្រឆាំងវីរុសនេះទេ ។ ការព្យាបាលផ្សេងទៀតរួមមាន ការផឹកទឹកឱ្យបានច្រើន សំរាក និង ប្រើឱសថ ប៉ារ៉ាសេតាម៉ុល ដើម្បីបញ្ចុះកំដៅ ។

**សូមទាក់ទងទូរស័ព្ទទាន់ហេតុការណ៍លេខ** : **១១៥, ០១២ ៤៨៨ ៩៨១, ០៨៩ ៦៦៩ ៥៦៧** ។

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង** : វេជ្ជ. **សុខ ទូច** : **០១២ ៨៥៦ ៨៤៨** វេជ្ជ. **លី សូវ៉ាន់** : **០១២ ៨២៥ ៤២៤**

**អង្គការសុខភាពពិភពលោក** : វេជ្ជ. **ម៉ៃឃល អូឈារី** : **០២៣ ២១៦ ៦១០** វេជ្ជ. **អាសហ្គារី នីម៉ា** : **០១២ ៤៤៣ ៨៧៧**

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា